# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងបរិស្ថាន | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ក្រសួងមហាផ្ទៃ

លេខ: ០៧៣ ប្រ.កប.ស្ក

## ប្រកាសអន្តរក្រសួង

## ស្តីពី

## ការប្រើប្រាស់កញ្ចប់ថវិកាសេវាអនាម័យបរិស្ថាន សម្រាប់អនុវត្តមុខងារ គ្រប់គ្រងសំណល់រឹង រាវ តាមទីប្រជុំជនក្រុងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ** | **រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** | **រដ្ឋមន្ត្រី ក្រសួងបរិស្ថាន**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែល ប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខនស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខនស/រកម/០៦១១/០១១ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបហិរញ្ញវត្ថុនិងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

- បានឃើញអនុក្រឹត្យលេខ១៦អនក្រ.បក ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ៤៨៨អនក្រ.បកចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ៥៧អនក្រ.បកចុះថ្ងៃទី២៥ខែកញ្ញា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ៨១ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតការត្រួត ពិនិត្យហិរញ្ញវត្ថុលើចំណាយថវិការដ្ឋនៅតាមក្រសួង ខេត្ត ក្រុង ក្រុងស្វយ័ត រាជធានីភ្នំពេញ និងអង្គការ សាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជា ទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ៦៨ អនក្រ.បក ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១២ ស្តីពីដំណើរការទូទៅនៃការផ្ទេរមុខងារនិងធនធានទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ ១៧២ អនក្រ.នក ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១២ ស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលក្រុង ស្រុក
- បានឃើញអនុក្រឹត្យលេខ២៣៩អនក្រ.បក ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៤ស្តីពីការកែ សម្រួលអត្រាអាករពិសេសលើមុខទំនិញមួយចំនួន
- បានឃើញអនុក្រឹត្យលេខ ៣៦ អនក្រ/បក ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការគ្រប់គ្រងសំណល់រឹង
- បានឃើញប្រកាសអន្តរក្រសួងលេខ ៣២៤ សហវ.ប្រក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៣ ស្តីពី នីតិវិធីនៃការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការលទ្ធកម្ម និងអង្គភាពលទ្ធកម្ម របស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- តាមការចាំបាច់របស់ក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងបរិស្ថាន

## សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**ប្រការ១._**

ប្រកាសនេះមានគោលបំណងពង្រឹងការគ្រប់គ្រង ការប្រើប្រាស់ធនធានថវិកាជាតិ ផ្តល់ជូនរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការពង្រឹងសេវាអនាម័យបរិស្ថាន សម្រាប់អនុវត្តមុខងារគ្រប់គ្រងសំណល់រឹង រាវ តាមទីប្រជុំជននៃរដ្ឋបាល ថ្នាក់ក្រោមជាតិប្រកបដោយតម្លាភាព គណនេយ្យភាព ប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព។

**ប្រការ២._**

ប្រកាសនេះមានគោលដៅកំណត់អំពីក្របខ័ណ្ឌគតិយុត្តិ សម្រាប់៖

- ការផ្តល់ ការផ្ទេរ និងការប្រើប្រាស់ធនធានហិរញ្ញវត្ថុមួយចំណែកពីថវិកាជាតិ និង
- ការត្រួតពិនិត្យ និងវាយតម្លៃលើការប្រើប្រាស់ធនធានហិរញ្ញវត្ថុ សម្រាប់អនុវត្តមុខងារគ្រប់គ្រងសំណល់រឹង រាវ តាមទីប្រជុំជននៃរដ្ឋបាលក្រុង។

**ប្រការ៣._**

ប្រកាសនេះមានវិសាលភាពអនុវត្តសេវាអនាម័យបរិស្ថាន សម្រាប់អនុវត្តមុខងារគ្រប់គ្រងសំណល់រឹង រាវ ជំហានដំបូងនៅតាមទីប្រជុំជនរបស់រដ្ឋបាលក្រុងទាំង២៦ នៃខេត្តទាំង២៤។

## ជំពូកទី ២
## ប្រភពធនធាន និងការគ្រប់គ្រង

**ប្រការ៤._**

ប្រភពធនធាននៃសេវាអនាម័យបរិស្ថាន រួមមាន៖

- ការផ្ទេរធនធានពីថវិកាជាតិ ដែលមានប្រភពចំណូលមកពី៖
  - ចំណែក២%នៃអាករពិសេសលើមុខទំនិញមួយចំនួន(ផលិតផលប្លាស្ទិច និងគ្រឿងអេឡិចត្រូនិក)
  - ចំណូលផ្សេងៗទៀតពីថវិកាជាតិ
- ការរួមចំណែកពីសប្បុរសជន
- ការរួមចំណែកពីដៃគូអភិវឌ្ឍ និងស្ថាប័នហិរញ្ញវត្ថុអន្តរជាតិនានា ក្រោមក្របខ័ណ្ឌហិរញ្ញប្បទានសហប្រតិបត្តិការ។

**ប្រការ៥._**

ក្នុងពេលរៀបចំកញ្ចប់ថវិកាប្រចាំឆ្នាំ(ចាប់ពីឆ្នាំ២០១៦ឡើងទៅ) ក្រសួងបរិស្ថាន និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវពិភាក្សា កំណត់ពីទំហំធនធានហិរញ្ញវត្ថុ ដែលនឹងត្រូវផ្ទេរជូនរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយផ្អែកលើលទ្ធផលនៃការអនុវត្តសកម្មភាពការងារជាក់ស្តែង និងការប្រើប្រាស់កញ្ចប់ថវិកាសេវាអនាម័យបរិស្ថាននៃឆ្នាំកន្លងមក។ ៕

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវជូនដំណឹងអំពីកញ្ចប់ថវិកាបឋមដោយផ្អែកតាមរូបមន្តដូចមានកំណត់ក្នុងប្រការ ៧ នៃប្រកាសនេះ ជូនរដ្ឋបាលក្រុងគោលដៅនីមួយៗ ដើម្បីរៀបចំបញ្ចូលក្នុងគម្រោងថវិកាប្រចាំឆ្នាំរបស់ខ្លួន។

**ប្រការ ៦._**

នៅក្នុងឆ្នាំថវិកានីមួយៗក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវរៀបចំអនុក្រឹត្យស្តីពីការផ្ទេរឥណទានថវិកា និងប្រកាសស្តីពីការផ្ទេរឥណទានថវិកាកញ្ចប់ថវិកាសេវាអនាម័យបរិស្ថានសម្រាប់រដ្ឋបាលក្រុងគោលដៅ។

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវបោះផ្សាយអាណត្តិបើកប្រាក់កញ្ចប់ថវិកាសេវាអនាម័យបរិស្ថានជាបួនដំហាន ដែលកំណត់ប្រចាំត្រីមាសជូនរដ្ឋបាលក្រុងដោយមានភ្ជាប់នូវតារាងបែងចែកថវិកាតាមក្រុងគោលដៅនីមួយៗតាមរយៈអគ្គនាយកដ្ឋានរតនាគារជាតិ។ នៅដើមត្រីមាសទី១ ក្រសួងសេដ្ឋកិច្ចនិង ហិរញ្ញវត្ថុនឹងផ្តល់ថវិកាសេវាអនាម័យបរិស្ថានដោយមិនចាំបាច់មានការស្នើសុំឡើយ។ ដោយឡែកសម្រាប់ ត្រីមាសទី២ ទី៣ និងទី៤ រដ្ឋបាលក្រុងគោលដៅនីមួយៗត្រូវធ្វើសំណើសុំឧបត្ថម្ភកញ្ចប់ថវិកាសេវាអនាម័យបរិស្ថានមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមរយៈមន្ទីរបរិស្ថានខេត្តដោយមានភ្ជាប់ឯកសារ លិខិតយុត្តិការ ដូចខាងក្រោម:

- របាយការណ៍អនុវត្តចំណូល ចំណាយប្រចាំខែ សម្រាប់ការអនុវត្តសេវាអនាម័យបរិស្ថានសម្រាប់អនុវត្តមុខងារគ្រប់គ្រងសំណល់រឹង រាវ និងលទ្ធផលការងារដែលសម្រេចបាន។
- របាយការណ៍ប៉ាន់ស្មានចំណូល ចំណាយប្រចាំត្រីមាស ត្រីមាសបន្ទាប់និងប្រចាំឆ្នាំសម្រាប់ការអនុវត្តសេវាអនាម័យបរិស្ថាន រួមទាំងឯកសារសម្រាប់គាំទ្រ(កិច្ចសន្យារវាងរដ្ឋបាលក្រុងនិងដៃគូផ្តល់សេវាអនាម័យបរិស្ថាន និងផែនការសកម្មភាពការងារសេវាអនាម័យបរិស្ថានគ្រប់គ្រងសំណល់រឹង រាវ).

## ជំពូកទី ៣
## ការបែងចែក ការប្រើប្រាស់ធនធាននិងការតាមដាន

**ប្រការ ៧._**

កញ្ចប់ថវិកាសេវាអនាម័យបរិស្ថាន ត្រូវបានបែងចែកទៅឱ្យរដ្ឋបាលក្រុងគោលដៅនីមួយៗ ផ្អែកតាមរូបមន្ត ដើម្បីធានាសមធម៌ និងតម្លាភាព។ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ធ្វើការគណនានិងបែងចែកធនធាននេះផ្អែកលើសន្ទស្សន៍ដូចខាងក្រោម:

- ចំណែកស្មើគ្នាជាមូលដ្ឋានមានចំនួន ៥០ភាគរយ ត្រូវបានបែងចែកក្នុងទំហំចំនួនស្មើៗគ្នាសម្រាប់រដ្ឋបាលក្រុងគោលដៅនីមួយៗ

- ប្រជាពលរដ្ឋមានចំនួន ៥០ភាគរយ ត្រូវបានបែងចែកទៅតាមសមាមាត្រនៃចំនួនប្រជាពលរដ្ឋនៃរដ្ឋបាលក្រុងគោលដៅនីមួយៗ ដោយផ្អែកតាមទិន្នន័យផ្លូវការរបស់ក្រសួងផែនការ។

**ប្រការ ៨._**

រដ្ឋបាលក្រុងគោលដៅនីមួយៗ ត្រូវធានាប្រើប្រាស់កញ្ចប់ថវិកាសេវាអនាម័យបរិស្ថាន ប្រកបដោយតម្លាភាព និងប្រសិទ្ធិភាពក្នុងការងារសេវាអនាម័យបរិស្ថាន សម្រាប់អនុវត្តមុខងារគ្រប់គ្រងសំណល់រឹង រាវ នៅក្នុងទីប្រជុំជនសាមីតែប៉ុណ្ណោះ។

**ប្រការ ៩._**

រដ្ឋបាលក្រុងគោលដៅនីមួយៗ ត្រូវ៖

- រៀបចំផែនការសកម្មភាពការងារសេវាអនាម័យបរិស្ថាន សម្រាប់អនុវត្តមុខងារគ្រប់គ្រងសំណល់រឹង រាវ
- គ្រោងចំណូល ចំណាយថវិកា សម្រាប់ការអនុវត្តសេវាអនាម័យបរិស្ថាន សម្រាប់អនុវត្តមុខងារគ្រប់គ្រងសំណល់រឹង រាវ ទៅក្នុងផែនការថវិកាប្រចាំឆ្នាំរបស់ខ្លួនទៅតាមទំហំធនធានថវិកាដែលទទួលបានពីថ្នាក់ជាតិ
- គ្រប់គ្រងលើការផ្តល់សេវាអនាម័យបរិស្ថាន សម្រាប់អនុវត្តមុខងារគ្រប់គ្រងសំណល់រឹង រាវ
- ជ្រើសរើសដៃគូផ្តល់សេវាអនាម័យបរិស្ថានគ្រប់គ្រងសំណល់រឹង រាវ ដោយអនុលោមតាមនីតិវិធីនិងវិធីសាស្ត្រលទ្ធកម្មរបស់រដ្ឋបាលក្រុងស្រុក និងនីតិវិធីហិរញ្ញវត្ថុជាធរមាន
- រៀបចំរបាយការណ៍ចំណាយប្រចាំត្រីមាសនិងប្រចាំឆ្នាំ និងលទ្ធផលការងារសេវាអនាម័យបរិស្ថាន សម្រាប់អនុវត្តមុខងារគ្រប់គ្រងសំណល់រឹង រាវ ដែលសម្រេចបាន។

**ប្រការ ១០._**

ក្រសួងបរិស្ថាន ត្រូវធ្វើការតាមដានត្រួតពិនិត្យ និងវាយតម្លៃលើកិច្ចប្រតិបត្តិការងារគ្រប់គ្រងសេវាអនាម័យបរិស្ថានសម្រាប់អនុវត្តមុខងារគ្រប់គ្រងសំណល់រឹងរាវ របស់រដ្ឋបាលក្រុងគោលដៅនីមួយៗជាប្រចាំ។

ក្រសួងបរិស្ថាន ត្រូវធ្វើការណែនាំបច្ចេកទេស លើការគ្រប់គ្រងសេវាអនាម័យបរិស្ថាន សម្រាប់អនុវត្តមុខងារគ្រប់គ្រងសំណល់រឹង រាវ ដល់រដ្ឋបាលក្រុង។

ក្រសួងបរិស្ថានត្រូវស្នើទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីផ្អាកការឧបត្ថម្ភកធនកញ្ចប់ថវិកាសេវាអនាម័យបរិស្ថាន ជូនរដ្ឋបាលក្រុង ក្នុងករណីដែលអនុវត្តខុសពីខ្លឹមសារនៃប្រកាសអន្តរក្រសួងនេះ ឬមិនអនុវត្តតាមការណែនាំរបស់ក្រសួងបរិស្ថានលើបច្ចេកទេសនៃការងារគ្រប់គ្រងសេវាអនាម័យបរិស្ថាន សម្រាប់អនុវត្តមុខងារការគ្រប់គ្រងសំណល់រឹង រាវ។

**ប្រការ ១១._**

ក្រសួងបរិស្ថានធ្វើសំណើទៅក្រសួងមហាផ្ទៃ ៖

- ផ្តល់ការសរសើរដល់រដ្ឋបាលក្រុងដែលអនុវត្តការងារគ្រប់គ្រងសេវាអនាម័យបរិស្ថាន សម្រាប់អនុវត្តមុខងារគ្រប់គ្រងសំណល់រឹង រាវ ប្រកបដោយតម្លាភាពនិងប្រសិទ្ធិភាព ឬ
- ព្រមាន ឬស្តីបន្ទោសចំពោះរដ្ឋបាលក្រុងណាដែលអនុវត្តការងារគ្រប់គ្រងសេវាអនាម័យបរិស្ថាន សម្រាប់អនុវត្តមុខងារគ្រប់គ្រងសំណល់រឹង រាវ មិនមានតម្លាភាពនិងប្រសិទ្ធិភាព ឬ មិនអនុវត្ត តាមការណែនាំបច្ចេកទេសរបស់ក្រសួងបរិស្ថានលើការងារគ្រប់គ្រងសេវាអនាម័យបរិស្ថាន សម្រាប់អនុវត្តមុខងារការគ្រប់គ្រងសំណល់រឹង រាវ។

**ប្រការ ១២._**

ក្រសួងមហាផ្ទៃ និងក្រសួងបរិស្ថាន ត្រូវចុះពិនិត្យនិងធ្វើការវាយតំលៃអំពីដំណើរការ និងលទ្ធផលប្រចាំឆ្នាំនៃការអនុវត្តរបស់រដ្ឋបាលក្រុងលើការគ្រប់គ្រងសេវាអនាម័យបរិស្ថាន សម្រាប់អនុវត្តមុខងារគ្រប់គ្រងសំណល់រឹង រាវ ក្នុងទីប្រជុំជនក្រុង ក្រោមកញ្ចប់ថវិកាសេវាអនាម័យបរិស្ថាន។

## ជំពូកទី ៤

## អន្តរប្បញ្ញត្តិ

**ប្រការ១៣._**

សម្រាប់ឆ្នាំ២០១៥ កញ្ចប់ថវិកាសេវាអនាម័យបរិស្ថាន សម្រាប់អនុវត្តមុខងារគ្រប់គ្រងសំណល់រឹង រាវ ដែលត្រូវផ្តល់ឱ្យរដ្ឋបាលក្រុង២៦ នៃខេត្តទាំង២៤ មានចំនួន ២០.០០០ លានរៀល(ម្ភៃពាន់លានរៀលគត់)។

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រៀបចំប្រកាសបន្ថែមឥណទានជូនរដ្ឋបាលក្រុងគោលដៅនីមួយៗអំពីធនធានដែលរដ្ឋបាលសាមី ត្រូវទទួលបានតាមការវិភាជន៍ដូចមានចែងក្នុងប្រការ ៧។ ចំពោះការស្នើសុំថវិកាសេវាអនាម័យបរិស្ថានរបស់រដ្ឋបាលក្រុងនីមួយៗត្រូវអនុវត្តតាមការកំណត់ក្នុងប្រការ៦។

## ជំពូកទី ៥
## អវសានប្បញ្ញត្តិ

**ប្រការ ១៤._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ១៥._**

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន ប្រធានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ក្រុមប្រឹក្សាខេត្ត អភិបាលនៃគណៈអភិបាលខេត្ត ក្រុមប្រឹក្សាក្រុង អភិបាលនៃគណៈអភិបាលក្រុង ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០១៥

| | | |
|---|---|---|
| **ឧបនាយករដ្ឋមន្ត្រីរដ្ឋមន្ត្រី** | **រដ្ឋមន្ត្រី** | **រដ្ឋមន្ត្រី** |
| **ក្រសួងមហាផ្ទៃ** | **ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** | **ក្រសួងបរិស្ថាន** |
| ស ខេង | បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន | សាយ សំអាល់ |

<u>កន្លែងទទួល៖</u>
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ១៥
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ